ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
លេខៈ ១០២៩៨២៣៦

# សារលិខិតថ្វាយព្រះពរ

## សូមក្រាបបង្គំទូលថ្វាយ
## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា
## នៅក្នុងព្រះរាជឱកាសពិធីខួបលើកទី២០ នៃការយាងគ្រងព្រះបរមសិរីរាជសម្បត្តិ

**ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត**

នៅក្នុងព្រះរាជឱកាសដ៏មហាសិរីមង្គលាភិរម្យវិសេសវិសាលប្រសើរថ្លៃថ្លាបំផុត នៃព្រះរាជពិធីខួបលើកទី២០នៃការយាងគ្រងព្រះបរមសិរីរាជសម្បត្តិរបស់ **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា** ដែលនឹងប្រព្រឹត្តទៅនាថ្ងៃអង្គារ ១២រោច ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២៩ ខែតុលា ឆ្នាំ២០២៤ ខាងមុខនេះ ទូលព្រះបង្គំជាខ្ញុំនិងភរិយា តាងនាមថ្នាក់ដឹកនាំនិងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់នៃទីស្តីការគណៈរដ្ឋមន្ត្រី សូមព្រះបរមរាជានុញ្ញាតដ៏ខ្ពង់ខ្ពស់សូមក្រាបថ្វាយនូវសេចក្តីអំណរសាទរឥតឧបមា និងសូមចូលរួមថ្វាយនូវព្រះសព្ទសាធុការពរជ័យ បវរសួស្តី សិរីមង្គល វិបុលសុខគ្រប់ប្រការថ្វាយចំពោះ **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត និងសូមព្រះអង្គទ្រង់សមប្រកបដោយព្រះរាជបញ្ញាញាណភ្លឺថ្លា ព្រះកាយពលរឹងមាំខ្លាំងក្លា ព្រះរាជសុខភាពល្អបរិបូរណ៍ ព្រះជន្មាយុយឺនយូរជាងរយព្រះវស្សា ចាកផុតពីព្រះរោគាព្យាធិនានា ដើម្បីព្រះអង្គទ្រង់គង់ប្រថាប់នៅក្នុងព្រះបរមសិរីរាជសម្បត្តិ យាងបំពេញព្រះរាជបូជនីយកិច្ច ដើម្បីជាតិ មាតុភូមិ ប្រជារាស្ត្រកម្ពុជា និងជានិមិត្តរូបនៃឯកភាពជាតិ និងនិរន្តរភាពជាតិ ព្រមទាំងជាព្រះម្លប់ដ៏ត្រជាក់ត្រជុំសម្រាប់ទូលព្រះបង្គំជាខ្ញុំ និងប្រជានុរាស្ត្រគ្រប់ៗរូបជ្រកកោនក្រោមព្រះតេជៈបារមី បានក្តីសុខក្សេមក្សាន្តជានិច្ចនិរន្តរ៍តរៀងទៅ។

បពិត្រ **ព្រះករុណាថ្លៃវិសេស** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត!

ទូលព្រះបង្គំជាខ្ញុំនិងភរិយា ព្រមទាំងថ្នាក់ដឹកនាំនិងមន្ត្រីរាជការទាំងអស់នៃទីស្តីការគណៈរដ្ឋមន្ត្រី សូមព្រះបរមរាជានុញ្ញាតដ៏ខ្ពង់ខ្ពស់សូមក្រាបអភិវន្ទថ្វាយនូវកតញ្ញុតាធម៌ និងកតវេទិតាធម៌ដ៏ជ្រាលជ្រៅបំផុតចំពោះព្រះករុណាថ្លៃវិសេសជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ចំពោះព្រះមហាករុណាទិគុណ ព្រះរាជតម្រិះដ៏ឈ្លាសវៃ និងព្រះរាជ

សកម្មភាពដ៏ឧត្តុង្គឧត្តមប្រពៃថ្លៃថ្លាបម្រើឧត្តមប្រយោជន៍ជាតិ និងជាពិសេសព្រះអង្គតែងមានទឹកព្រះទ័យជ្រះថ្លាបរិសុទ្ធ ប្រកបដោយទសពិធរាជធម៌ ទ្រង់សព្វព្រះរាជហឫទ័យប្រោសព្រះរាជទានព្រះរាជទ្រព្យយ៉ាងច្រើនជាបន្តបន្ទាប់ជួយក្នុងវិស័យមនុស្សធម៌ សង្គមកិច្ច វប្បធម៌ អប់រំ សាសនា សុខុមាលភាព យុទ្ធនាការបោសសម្អាតមីននៅកម្ពុជា ការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជានុរាស្ត្រ ព្រមទាំងព្រះរាជសកម្មភាពនានាជាច្រើនទៀត ដែលបានរួមចំណែកយ៉ាងសំខាន់ដល់ការលើកកម្ពស់កិត្យានុភាពជាតិដ៏ឧត្តមត្រដែតលើឆាកអន្តរជាតិ និងការជំរុញកិច្ចអភិវឌ្ឍមាតុភូមិកម្ពុជាលើគ្រប់វិស័យ។

ឆ្លៀតក្នុងព្រះរាជឱកាសដ៏មហានក្ខត្តឫក្សប្រពៃថ្លៃថ្លាបំផុតនេះ ទូលព្រះបង្គំជាខ្ញុំទាំងអស់ សូមព្រះបរមរាជានុញ្ញាតដ៏ខ្ពង់ខ្ពស់ជាថ្មីម្តងទៀត សូមលើកហត្ថប្រណម្យបួងសួងដល់វត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក គុណបុណ្យព្រះរតនត្រ័យ គុណកែវទាំងបី ទេវតាថែរក្សាព្រះមហាស្វេតច្ឆត្រ បុណ្យបារមីនៃដួងព្រះវិញ្ញាណក្ខន្ធអតីតព្រះមហាក្សត្រ ព្រះមហាក្សត្រិយានីខ្មែរគ្រប់ព្រះអង្គ ជាពិសេសបុណ្យបារមីនៃដួងព្រះវិញ្ញាណក្ខន្ធ **ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ ព្រះបរមរតនកោដ្ឋ** និងទេវតាថែរក្សាឆ្នាំរោង ឆស័ក ព្រះនាម **មហោទរាទេវី** សូមព្រះអង្គតាមជួយថែរក្សាការពារ អភិបាល ប្រោះព្រំនូវព្រះសព្ទសាធុការពរជ័យគ្រប់ប្រការ និងសូមព្រះករុណាថ្លៃវិសេស ព្រះអង្គទ្រង់សមប្រកបដោយព្រះពុទ្ធពរដ៏ឧត្តុង្គឧត្តមថ្លៃថ្លាទាំងបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ និងពលៈ** ជានិច្ចនិរន្តរ៍ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត** ទ្រង់ព្រះមេត្តាទទួលនូវអភិវន្ទនកិច្ច និងគារវភក្តីដ៏ស្មោះស្ម័គ្របំផុតពីទូលព្រះបង្គំជាខ្ញុំនិងភរិយា។

ថ្ងៃ សុក្រ ៨ រោច ខែ អស្សុជ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ២០២៤

**តាងនាមថ្នាក់ដឹកនាំនិងមន្ត្រីរាជការនៃទីស្តីការគណៈរដ្ឋមន្ត្រី**

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**វង្សី វិស្សុត**